បទដ្ឋានស្នូល
មនុស្សធម៌

# បទដ្ឋានស្នូលមនុស្សធម៌ស្ដីពី
# គុណភាព និងគណនេយ្យភាព

**បោះពុម្ពផ្សាយដោយ**: សម្ព័ន្ធភាពបទដ្ឋានស្នូលមនុស្សធម៌ (CHS Alliance) ក្រុម URD និងគម្រោងការស្វ៊ែរ (The Sphere Project)

**កែសម្រួលលើទី១**: **២០១៤**

**ISBN: 978-2-9701015-5-0**
រក្សាសិទ្ធិគ្រប់យ៉ាង។ រាល់ឯកសារដែលមាននៅទីនេះត្រូវបានរក្សាសិទ្ធិដោយ សម្ព័ន្ធភាពបទដ្ឋានស្នូលមនុស្សធម៌ ក្រុម URD និងគម្រោងការស្វ៊ែរ វាអាចត្រូវបានបោះពុម្ពផ្សាយឡើងវិញក្នុងគោលបំណងអប់រំ រួមបញ្ចូលទាំងវគ្គបណ្តុះបណ្តាល ការស្រាវជ្រាវ និងសកម្មភាពកម្មវិធីផ្សេងៗទៀតត្រូវបានអនុញ្ញាតិ និងទទួលស្គាល់ពីបទដ្ឋាន ស្នូលមនុស្សធម៌ស្តីពីគុណភាព និងគណនេយ្យភាព។ រាល់ការបកប្រែ ឬកែសម្រួលផ្នែកណាមួយ នៃបទដ្ឋានស្នូលមនុស្សធម៌ស្តីពី គុណភាព និងគណនេយ្យភាព ត្រូវតែសុំការអនុញ្ញាតិជាមុនតាមរយៈអ៊ីមែល
info@corehumanitarianstandard.org

# អារម្ភកថា

បទដ្ឋានស្នូលមនុស្សធម៌ស្ដីអំពីគុណភាព និងគណនេយ្យភាព (CHS) ជាលទ្ធផលមួយបានមកពីគំនិតផ្ដួចផ្ដើមរួមគ្នាលើបទដ្ឋាន ដែលក្នុងនោះដៃគូសហប្រតិបត្តិការអន្តរជាតិស្ដីពីគណនេយ្យភាពផ្នែកមនុស្សធម៌ (HAP) ភីផលអ៊ីនអេដ (People In Aid) និងគម្រោងស្ហ្វៀរ (Sphere Project) ធ្វើការរួមគ្នាដើម្បីធ្វើឱ្យមានភាពប្រសើរឡើងសម្រាប់អ្នកប្រើប្រាស់បទដ្ឋានមនុស្សធម៌។ គំនិតផ្ដួចផ្ដើមនេះត្រូវបានពិគ្រោះយោបល់ជាមួយភ្នាក់ងារមនុស្សធម៌ជាង ២០០០នាក់ មកពីការិយាល័យកណ្ដាល ពីក្នុងតំបន់ និងប្រទេសដែលប្រឈមទៅនឹងគ្រោះមហន្តរាយ។ តាមរយៈមតិត្រឡប់បានបញ្ជាក់ពីតម្រូវការសម្រាប់ភាពបន្សុីគ្នានៃបទដ្ឋានជាមួយនឹងសហគមន៍ និងប្រជាជនដែលរងគ្រោះដោយគ្រោះមហន្តរាយ ដែលជាស្នូលនិងជាគោលការណ៍មនុស្សធម៌សម្រាប់ជាមូលដ្ឋានគ្រឹះ។

បទដ្ឋានស្នូលមនុស្សធម៌ ជាលទ្ធផលនៃការពិគ្រោះយោបល់រយៈពេល១២ខែក្នុង៣ដំណាក់កាល ដែលក្នុងអំឡុងពេលនោះ ភ្នាក់ងារមនុស្សធម៌ សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ អង្គការមិនមែនរដ្ឋាភិបាលបណ្ដាញផ្សេងៗ រដ្ឋាភិបាល អង្គការសហប្រជាជាតិ ម្ចាស់មូលនិធិ និងស្ថាប័នសិក្សាបានវិភាគយ៉ាងហ្មត់ចត់ទៅលើខ្លឹមសារនៃបទដ្ឋានស្នូលមនុស្សធម៌ ហើយបានសាកល្បងនៅទីស្នាក់ការកណ្ដាល និងនៅមូលដ្ឋាន។

មតិត្រឡប់ពីការប្រឹក្សាយោបល់នីមួយៗត្រូវបានពិចារណា និងត្រួតពិនិត្យឡើងវិញ ហើយត្រូវបានអនុម័តពីក្រុមទីប្រឹក្សាបច្ចេកទេសចំនួន៦៥នាក់ ដែលតំណាងឱ្យស្ថាប័នជាច្រើន និងមានជំនាញបច្ចេកទេសលើកិច្ចការមនុស្សធម៌ និងការរៀបចំបទដ្ឋានផ្សេងៗ។

ជាចេតនារបស់ក្រុមប្រឹក្សាភិបាលនៃ HAP ភីផលអ៊ីនអេដ និងគម្រោងស្ហ្វៀរ គឺថាបទដ្ឋានស្នូលមនុស្សធម៌នឹងត្រូវជំនួសបទដ្ឋាន HAP ស្ដីពីគណនេយ្យភាព និងការគ្រប់គ្រងគុណភាព និងបែបបទរបស់ភីផលអ៊ិនអេដលើការអនុវត្តល្អស្ដីពីការគ្រប់គ្រង និងការគាំទ្រដល់បុគ្គលិកមនុស្សធម៌ និងផ្នែកបទដ្ឋានស្នូលរបស់គម្រោងស្ហ្វៀរ។

# សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះអង្គការ និងបុគ្គលជាច្រើនដែលបានចូលរួមបង្កើតបទដ្ឋានស្នូលមនុស្សធម៌នេះឡើងតាមរយៈការផ្ដល់មតិត្រឡប់លើពង្រាងនៃបទដ្ឋានស្នូលមនុស្សធម៌ និងការសាកល្បងប្រើប្រាស់បទដ្ឋាននេះក្នុងអង្គការរបស់ខ្លួន[1] ឬចូលរួមក្នុងក្រុមតាមដានលើដំណើរការពិគ្រោះយោបល់។ ការចូលរួមចម្រុះគ្នាពីសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយតាមរយៈការពិគ្រោះយោបល់ និងដំណើរការអនុវត្តសាកល្បងត្រូវបានទទួលការស្វាគមន៍យ៉ាងកក់ក្ដៅ។

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបន្សុីបទដ្ឋានទាំងនោះ HAP ភីផលអ៊ិនអេដ និងគម្រោងស្ហ្វៀរសហការជាមួយក្រុម URD ដែលធ្វើសមាហរណកម្មគ្រោងការគុណភាព COMPAS ក្នុងបទដ្ឋានស្នូលមនុស្សធម៌។ ក្រុមពិគ្រោះយោបល់ផ្នែកបច្ចេកទេសរបស់បទដ្ឋានស្នូលមនុស្សធម៌ និងអនុក្រុមរបស់

[1] បញ្ជីរាយនាមឈ្មោះអង្គការដែលធ្វើការសាកល្បងប្រើប្រាស់បទដ្ឋានស្នូលអាចរកបានតាមរយៈ www.corehumanitarianstandard.org

ខ្លួន និងគណៈកម្មាធិការដឹកនាំផ្នែកបច្ចេកទេសទទួលខុសត្រូវត្រួតពិនិត្យមើលដំណើរការពិគ្រោះយោបល់ និងការអនុម័តចុងក្រោយលើបទដ្ឋានស្នូលមនុស្សធម៌។ ក្រុមសរសេរបទដ្ឋានស្នូលមនុស្សធម៌មានតួនាទីកែសម្រួលបទដ្ឋានស្នូលមនុស្សធម៌ ដោយដាក់បញ្ចូលរាល់មតិត្រឡប់ដែលបានទទួលពីគ្រប់ដំណាក់កាលនៃការពិគ្រោះយោបល់។

ដើម្បីឱ្យប្រាកដថាលទ្ធផលដែលទទួលបានវាជាតំណាងដែលស្របតាមវត្ថុបំណង ដំណើរការពិគ្រោះយោបល់របស់បទដ្ឋានស្នូលមនុស្សធម៌ ត្រូវបានសម្របសម្រួលដោយក្រុមប្រឹក្សាឯករាជ្យមួយមានឈ្មោះថាក្រុមចចក (Wolf Group)។ បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាបច្ចេកទេស គណៈកម្មាធិការដឹកនាំផ្នែកបច្ចេកទេស និងក្រុមសរសេរបទដ្ឋានស្នូលអាចរកបានក្នុងគេហទំព័រwww.corehumanitarianstandard.org។ ប្រសិនបើគ្មានការគាំទ្រដែលមិនចេះនឿយហត់ពីពួកគាត់ទាំងអស់គ្នាទេ ការប្រឹក្សាយោបល់លើបទដ្ឋានស្នូលមនុស្សធម៌ក៏មិនអាចប្រព្រឹត្តទៅបានដែរ។

ដំណើរការរបស់បទដ្ឋានស្នូលមនុស្សធម៌ត្រូវបានគាំទ្រយ៉ាងសប្បុរសតាមរយៈគម្រោងជាច្រើន ដែលទទួលថវិកាគាំទ្រពីម្ចាស់មូលនិធិដូចជា នាយកដ្ឋានរដ្ឋាភិបាលអូស្ត្រាលីស្តីពីកិច្ចការបរទេស និងពាណិជ្ជកម្ម ទីភ្នាក់ងារកាតូលិកសម្រាប់ការអភិវឌ្ឍក្រៅប្រទេស (CAFOD) ក្រសួងកិច្ចការបរទេសរបស់ប្រទេសដាណឺម៉ាក (Danida) ការិយាល័យបរទេសសម្រាប់សហព័ន្ធសាធារណរដ្ឋប្រទេសអាឡឺម៉ង់ ជំនួយអៀរឡង់ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែដ ទីភ្នាក់ងារស្វីសសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍ ជំនួយចក្រភពអង់គ្លេសមកពីរដ្ឋាភិបាលចក្រភពអង់គ្លេស និងរដ្ឋាភិបាលសហរដ្ឋអាមេរិក។

HAP ភីផលអ៊ីនអេដ និងគម្រោងស្ហ្វែរសូមថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលសម្រាប់ការបរិច្ចាគថវិកាគាំទ្ររាល់ដំណើរការបង្កើតបទដ្ឋានស្នូលមនស្សធម៌ដូចជា ACT Alliance អង្គការអាក់សិនអេតអន្តរជាតិ Aktion Deutschland Hilft, កាកបាទក្រហមចក្រភពអង់គ្លេស អង្គការ CAFOD អង្គការឃែរអន្តរជាតិ អង្គការChristian Aid អង្គការស៊ីដាប់បិលយូអេសប៉ាគីស្ថាន អាហ្គានីស្ថាន អង្គការជំនួយព្រះវិហារដាណឺម៉ាក អង្គការ Lutheran World Federation អង្គការ Save the Children International អង្គការSave the Children US និងអង្គការ ទស្សនៈពិភពលោកអន្តរជាតិ។

បទដ្ឋានស្នូលមនុស្សធម៌ត្រូវបានរៀបចំបកប្រែជាខេមរភាសាដោយបណ្តាញគណនេយ្យភាពមនុស្សធម៌នៅកម្ពុជា (Humanitarian Accountability Network in Cambodia-HANet)។ សូមថ្លែងអំណរគុណចំពោះលោកស្រី ទេស សោភ័ណ្ឌសម្រាប់ការសម្របសម្រួលរួមក្នុងការបកប្រែ និងបោះពុម្ពបទដ្ឋាននេះ លោក សួរ សុជាតិ លោក ឡឹក សុធារ និងលោក មុី ឡុង សម្រាប់ការត្រួតពិនិត្យកែសម្រួលខ្លឹមសារបច្ចេកទេស និងអក្ខរាវិរុទ្ធ។

## មតិត្រឡប់

សូមស្វាគមន៍រាល់យោបល់កែលម្អទាំងអស់គ្រប់ពេលវេលាលើបទដ្ឋានស្នូលមនុស្សធម៌នេះ។ សូមផ្ញើសំនួរ ពាក់ព័ន្ធនានាទៅកាន់info@corehumanitarianstandard.org ។

## ការត្រួតពិនិត្យ

យោបល់ទាំងអស់ដែលបានទទួលនឹងត្រូវបង្ហាញក្នុងការត្រួតពិនិត្យឡើងវិញរបស់បទដ្ឋានស្នូលមនុស្សធម៌ដែលនឹងត្រូវធ្វើឡើងមិនលើសពីខែធ្នូ ឆ្នាំ២០១៩។ សម្រាប់ព័ត៌មានបន្ថែមពីលើបទដ្ឋានស្នូលមនុស្សធម៌ ធនធាន និងឯកសារផ្សេងៗអាចរកបាននៅក្នុងគេហទំព័រ www.corehumanitarian-standard.org ។

## កំណត់សំគាល់ចំពោះការបកប្រែ

បទដ្ឋានស្នូលមនុស្សធម៌ អាចរកបានជាភាសាអារ៉ាប់ បារាំង និងអេស្ប៉ាញ។ ប្រសិនបើអ្នកចង់កែសម្រួលជា ភាសាដទៃទៀតសូមទាក់ទងតាម info@corehumanitarianstandard.org សម្រាប់ការណែនាំទៅលើការបកប្រែ។ គ្រប់ការបកប្រែទាំងអស់មិនត្រូវបានគិតកម្រៃទេ អ្នកអាចរកឯកសារទាំងអស់បានតាមរយៈគេហទំព័រ www.corehumanitarianstandard.org។

## សម្ភារដែលទាក់ទង

សេចក្តីណែនាំ និងឧបករណ៍នានា ដើម្បីជួយគាំទ្រដល់កម្មវិធីរបស់បទដ្ឋានស្នូលមនុស្សធម៌មិនត្រូវបានគិតកម្រៃទេ ហើយអាចរកបានតាមរយៈគេហទំព័រ www.corehumanitarianstandard.org។

## មាតិកា


១. សេចក្ដីផ្ដើម ........ ២-៣

២. វចនាសម្ព័ន្ធរបស់បទដ្ឋានស្នូលមនុស្សធម៌ស្ដីពីគុណភាព និងគណនេយ្យភាព ........ ៥

៣. ការអនុវត្តបទដ្ឋានស្នូលមនុស្សធម៌ ........ ៦

៤. អំណះអំណាង ........ ៧

៥. គោលការណ៍សកម្មភាពមនុស្សធម៌ ........ ៨

៦. ការប្ដេជ្ញាទាំងប្រាំបួន និងលក្ខណៈវិនិច្ឆ័យគុណភាព ........ ១០

៧. ការប្ដេជ្ញា សកម្មភាពគន្លឹះ និងការទទួលខុសត្រូវ ........ ១២

១. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយយ៉ាងសមរម្យ និងសមស្រប ទៅនឹងសេចក្ដីត្រូវការរបស់ពួកគេ ........ ១២

២.សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយមនុស្សធម៌ដែលពួកគេ ត្រូវការទាន់ពេលវេលា ........ ១៣

៣. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយមិនរងគ្រោះកាន់តែធ្ងន់ថែមទៀតប៉ុន្តែគេកាន់ តែត្រៀមបានល្អធន់ និងមានហានិភ័យទាបដែលជាលទ្ធផលនៃជំនួយមនុស្សធម៌ ........ ១៤

៤. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយយល់ដឹងអំពីសិទ្ធិរបស់ពួកគេ និងដឹងអ្វី ដែល គេត្រូវទទួលបាននិងអាចទទួលបានព័ត៌មាន ព្រមទាំងអាចចូលរួមក្នុងការសម្រេច ចិត្តលើការងារ ដែលពាក់ព័ន្ធនឹងពួកគេ ........ ១៦

៥. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានយន្តការដោះស្រាយបណ្ដឹងត៉វ៉ា ទាន់ពេលវេលានិងប្រកបដោយសុវត្ថិភាព ........ ១៧

៦. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយដែលមាន កិច្ចសហប្រតិការ និងបំពេញបន្ថែម ........ ១៨

៧. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយអាចរំពឹងថា បានទទួលជំនួយដែលមាន ការកែលម្អ ពីព្រោះអង្គការបានរៀនសូត្រពីបទពិសោធន៍ និងការឆ្លុះបញ្ចាំង ........ ១៩

៨. សហគមន៍ និងជនរងដោយគ្រោះមហន្តរាយទទួលបានជំនួយ ដែលពួកគេត្រូវការពី ភ្នាក់ងារ និងអ្នកស្ម័គ្រចិត្ត ដែលមានសមត្ថភាពត្រឹមត្រូវ និងគ្រប់គ្រងបានល្អ ........ ២០

៩. សហគមន៍ និងជនដែលរងគ្រោះដោយគ្រោះមហន្តរាយអាចរំពឹងថាអង្គការដែលជួយពួកគេមាន ការគ្រប់គ្រងធនធានដ៏មានប្រសិទ្ធិភាពត្រឹមត្រូវ និងប្រកបដោយក្រមសីលធម៌........ ២១

៨. សទ្ទានុក្រម ........ ២២

# បទដ្ឋានស្នូលមនុស្សធម៌ស្តីពី គុណភាព និងគណនេយ្យភាព

## ១. សេចក្តីផ្តើម

ជារៀងរាល់ថ្ងៃ នៅទូទាំងពិភពលោកមានមនុស្សរាប់មិនអស់មកពីគ្រប់ស្រទាប់វណ្ណៈបានផ្លាស់ប្តូរទៅធ្វើសកម្មភាពឆ្លើយតបជំនួយនិងអនុវត្តផ្នែកមនុស្សធម៌ បំណងប្រាថ្នាដើម្បីការពារ និងកាត់បន្ថយភាពរងទុក្ខវេទនារបស់មនុស្សនៅគ្រប់ទីកន្លែងដែលគ្រោះមហន្តរាយបានកើតឡើង។

បទដ្ឋានស្នូលមនុស្សធម៌ស្តីពីគុណភាព និងគណនេយ្យភាព កំណត់ការប្តេជ្ញាចំនួន ៩ ដែលអង្គការ និងបុគ្គលដែលធ្វើការឆ្លើយតបផ្នែកជំនួយមនុស្សធម៌អាចប្រើប្រាស់បាន ដើម្បីកែលម្អគុណភាព និងប្រសិទ្ធភាពនៃជំនួយដែលពួកគេបានផ្តល់ឱ្យ។ វាសម្របសម្រួលឱ្យកាន់តែមានគណនេយ្យភាពច្រើនជាងមុនដល់សហគមន៍ និងអ្នកដែលរងផលប៉ះពាល់ដោយវិបត្តិ ដោយដឹងពីអ្វីដែលអង្គការមនុស្សធម៌បានប្តេជ្ញាជំរុញឲ្យពួកគេមានគណនេយ្យភាពទៅលើការប្តេជ្ញាចិត្តទាំងនោះ។

បទដ្ឋានស្នូលមនុស្សធម៌យកសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយជាស្នូលសម្រាប់សកម្មភាពមនុស្សធម៌ និងជំរុញការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន។ សិទ្ធិទាំងនោះរួមមានសិទ្ធិរស់រានមានជីវិតប្រកបដោយភាពថ្លៃថ្នូរ និងសិទ្ធិទទួលបានកិច្ចការពារនិងសន្តិសុខ ដែលមានចែងក្នុងច្បាប់អន្តរជាតិ រួមទាំងនៅក្នុងច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស។[2]

ជាបទដ្ឋានស្នូលមួយ បទដ្ឋានស្នូលមនុស្សធម៌ពិពណ៌នាពីធាតុសំខាន់ៗនៃសកម្មភាពមនុស្សធម៌ប្រកបដោយគុណភាពខ្ពស់គណនេយ្យភាព និងគុណធម៌។ អង្គការមនុស្សធម៌អាចប្រើវាជាក្រមសីលធម៌ដោយស្ម័គ្រចិត្តដែលស្របនឹងនីតិវិធីផ្ទៃក្នុងរបស់ខ្លួន។ វាក៏អាចត្រូវបានគេប្រើជាមូលដ្ឋានសម្រាប់ផ្ទៀងផ្ទាត់ការអនុវត្តការងារដែលមានក្របខ័ណ្ឌជាក់លាក់មួយ និងសូចនាករដែលភ្ជាប់ជាមួយត្រូវបានបង្កើតឡើងដើម្បីធានាបាននូវភាពជាក់លាក់ឱ្យស្របទៅនឹងបរិបទ និងប្រភេទអង្គការផ្សេងៗពីគ្នា។

បទដ្ឋានស្នូលមនុស្សធម៌ អាចត្រូវបានជំរុញ និងអនុវត្តដោយបុគ្គល អង្គការ ក្រុមសម្របសម្រួល

[2] សិទ្ធិមនុស្សអន្តរជាតិរួមមានសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សអនុសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សិទ្ធិសង្គម និងវប្បធម៌ និងអនុសញ្ញាអន្តរជាតិស្តីពីពលរដ្ឋ និងនយោបាយ និងពិធីសារបន្ថែម។

បណ្ដាក្រុមសហការណ៍គ្នា និងក្រុមផ្សេងទៀតដែលមានសកម្មភាព ឬការរួមចំណែកទាក់ទងនឹងសកម្មភាពមនុស្សធម៌។ ទោះបីជាគោលបំណងជាចម្បងសម្រាប់វិស័យមនុស្សធម៌ក៏ដោយ ក៏បទដ្ឋានស្នូលមនុស្សធម៌នេះអាចត្រូវបានប្រើប្រាស់ដោយ អង្គការណាមួយ ដើម្បីនាំយកមកនូវគុណភាព និងគណនេយ្យភាពកាន់តែល្អប្រសើរគ្រប់ទិដ្ឋភាពទាំងអស់នៃការងាររបស់ខ្លួនជាមួយសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ។

បទដ្ឋានស្នូលមនុស្សធម៌ គឺជាលទ្ធផលនៃដំណើរការពិគ្រោះយោបល់ជាសាកល។ ជាមួយគ្នានេះដែរ វាបានបង្ហាញពីធាតុសំខាន់ៗនៃបទដ្ឋានមនុស្សធម៌ និងការប្ដេជ្ញាដែលមានស្រាប់។ ធាតុ និងការប្ដេជ្ញាចិត្តទាំងនេះរួមមាន ប៉ុន្ដែមិនត្រូវបានកំណត់ព្រំដែនលើ៖

- ក្រមសីលធម៌សម្រាប់កាកបាទក្រហម និងចលនាអឌ្ឍចន្ទក្រហមអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្ដល់ជំនួយសង្គ្រោះបន្ទាន់
- បទដ្ឋាន HAP ឆ្នាំ2010 ពីគណនេយ្យភាព និងការគ្រប់គ្រងគុណភាព
- ក្រមសីលធម៌របស់ភីផលអ៊ីនអេដ ស្ដីពីការគ្រប់គ្រង និងការគាំទ្របុគ្គលិកផ្ដល់ជំនួយ
- បទដ្ឋានស្នូលរបស់ស្វែរ និងធម្មនុញ្ញមនុស្សធម៌
- គុណភាព COMPAS
- ការប្ដេជ្ញារបស់គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារស្ដីពី គណនេយ្យភាពចំពោះប្រជាពលរដ្ឋរងផលប៉ះពាល់ និង
- អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់អង្គការ OECD គណៈកម្មាធិការជំនួយអភិវឌ្ឍលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃការអភិវឌ្ឍ និងជំនួយមនុស្សធម៌

# បទដ្ឋានស្នូលមនុស្សធម៌ស្តីពីគុណភាព និងគណនេយ្យភាព



## ២. រចនាសម្ព័ន្ធរបស់បទដ្ឋានស្នូលមនុស្សធម៌ ស្ដីពីគុណភាព និង គណនេយ្យភាព

បទដ្ឋានស្នូលមនុស្សធម៌ នេះគឺជាសំណុំនៃការប្ដេជ្ញាទាំង៩ចំពោះសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយបញ្ជាក់ពីអ្វីដែលពួកគេរំពឹងពីអង្គការ និងបុគ្គលដែលផ្ដល់ជំនួយមនុស្សធម៌។ ការប្ដេជ្ញានីមួយៗ ត្រូវបានគាំទ្រដោយលក្ខណៈវិនិច្ឆ័យគុណភាពដែលចង្អុលបង្ហាញពីរបៀបដែលអង្គការមនុស្សធម៌ និងបុគ្គលិក គួរអនុវត្តការងារ ដើម្បីស្របទៅនឹងបទដ្ឋានទាំងនោះ។ បទដ្ឋានស្នូលមនុស្សធម៌មានរចនាសម្ព័ន្ធដូចតទៅ៖

- ការប្ដេជ្ញាទាំង ៩
- ការគាំទ្រលក្ខណៈវិនិច្ឆ័យគុណភាព
- សកម្មភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចការប្ដេជ្ញាទាំងនោះ
- ការទទួលខុសត្រូវក្នុងការគាំទ្រ សម្រាប់ការអនុវត្តជាប្រព័ន្ធ និងស៊ីគ្នាទៅនឹងសកម្មភាពអនុវត្តទូទាំងស្ថាប័ន។ សកម្មភាពគន្លឹះ និងការទទួលខុសត្រូវពិពណ៌នាអំពី៖
- អ្វីដែលបុគ្គលិកបានចូលរួមនៅក្នុងសកម្មភាពមនុស្សធម៌ គួរធ្វើ ដើម្បីផ្ដល់នូវគុណភាពខ្ពស់។ កម្មវិធីដែល ជាប់លាប់ និងដើម្បីមានគណនេយ្យភាពចំពោះគ្រប់ប្រជាជនដែលគេផ្ដល់ជំនួយ
- គោលនយោបាយ ដំណើរការ និងប្រព័ន្ធការងាររបស់អង្គការដែលទាក់ទងនឹងសកម្មភាពមនុស្សធម៌ត្រូវតែបង្កើតឡើង ដើម្បីធានាថាបុគ្គលិករបស់ខ្លួនផ្ដល់នូវគុណភាពខ្ពស់ និងមានគណនេយ្យភាពក្នុងការផ្ដល់ជំនួយមនុស្សធម៌។

សទ្ទានុក្រមពាក្យដែលបានប្រើក្នុងបទដ្ឋានស្នូលមនុស្សធម៌ ជាមួយនឹងនិយមន័យជាក់លាក់បានដាក់បញ្ចូលនៅចុងបញ្ចប់នៃសៀវភៅនេះ។

# ៣. ការអនុវត្តបទដ្ឋានស្នូលមនុស្សធម៌

អង្គការដែលកំពុងនឹងប្ដេជ្ញាទៅ CHS គោលបំណងគឺបំពេញឱ្យការប្ដេជ្ញាទាំងប្រាំបួនដូចជាបទដ្ឋានអប្បបរមាមួយពួកគេត្រូវបានរំពឹងថានឹងធ្វើការ ដើម្បីបន្តកែលម្អប្រព័ន្ធរចនាសម្ព័ន្ធរបស់ពួកគេ និងការអនុវត្តជាក់ស្ដែង ដើម្បីបង្កើនគុណភាព និងគណនេយ្យភាពរបស់ពួកគេក្នុងការឆ្លើយតបជំនួយមនុស្សធម៌។ បើទោះជាយ៉ាងណាក៏ដោយ អង្គការ និងបុគ្គលដែលធ្វើការទាក់ទងនឹងសកម្មភាពមនុស្សធម៌គឺមានចម្រុះ។ ពួកគេត្រូវធ្វើសកម្មភាពឱ្យទាន់ពេលវេលា និងសម្របសម្រួលសកម្មភាពរបស់ពួកគេឱ្យស្របនឹងសមត្ថភាព និងអាណត្តិនៃអង្គការរបស់ពួកគេ ក៏ដូចជាដំណាក់កាល និងកាលៈទេសៈនៃគ្រោះមហន្តរាយ ដែលពួកគេកំពុងធ្វើការ។

នៅពេលដែលអង្គការជួបប្រទះការលំបាកក្នុងការបំពេញនូវការប្ដេជ្ញាទាំង ៩ ពួកគេគួរតែទទួលស្គាល់វា និងស្វែងរកដំណោះស្រាយលើបញ្ហាទាំងនោះតាមរបៀបណាមួយ ដើម្បីការពារពួកគេបាន។ អង្គការគួររៀនពីស្ថានភាពបែបហ្នឹងដើម្បីរិះរកវិធីសាស្ត្រដោះស្រាយ និងជម្នះលើឧបសគ្គដែលជួបប្រទះ។

ការវិភាគណាមួយទៅលើកម្មវិធីរបស់បទដ្ឋានស្នូលមនុស្សធម៌ គួរតែត្រូវបានផ្អែកលើកម្រិតដែលអង្គការបានកំណត់ ដើម្បីឱ្យសម្រេចបាននូវការប្ដេជ្ញាទាំង៩ និងមិនត្រឹមតែសកម្មភាពគន្លឹះត្រូវបានអនុវត្ត និងឬការទទួលខុសត្រូវរបស់អង្គការក៏ត្រូវបានបន្ទូបន្ថយ។ បទដ្ឋានស្នូលមនុស្សធម៌តម្រូវឱ្យអនុវត្តសកម្មភាពគន្លឹះ ដូច្នោះចាំបាច់ត្រូវតែធ្វើឱ្យវាស្របទៅនឹងបរិបទ។

បទដ្ឋានស្នូលមនុស្សធម៌ អាចអនុវត្តបាន សម្រាប់អង្គការ និងបុគ្គលដូចខាងក្រោម៖

- ផ្ដល់ជំនួយដោយផ្ទាល់ដល់សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ
- គាំទ្រផ្នែកហិរញ្ញវត្ថុ សម្ភារ ឬផ្នែកបច្ចេកទេសដល់អង្គការផ្សេងទៀត ប៉ុន្តែមិនត្រូវធ្វើដោយផ្ទាល់ក្នុងការផ្ដល់ជំនួយ ឬ
- បញ្ចូលគ្នាទាំងពីរវិធីសាស្ត្រខាងលើ

បទដ្ឋានស្នូលមនុស្សធម៌នេះ ត្រូវបានបង្កើតឡើង ដើម្បីប្រើប្រាស់តាមវិធីសាស្ត្រជាច្រើនពីគ្រប់អ្នកដែលធ្វើការងារទាក់ទងនឹងសកម្មភាពមនុស្សធម៌។ វិធីសាស្ត្រទាំងនោះមានដូចជា៖

- ជួយសម្រួលឱ្យកាន់តែមានគណនេយ្យភាពច្រើនជាងមុនចំពោះសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ និងការកែលម្អគុណភាពនៃការផ្ដល់សេវារបស់ពួកគេ
- បង្កើតផែនការការងារសម្រាប់ការអនុវត្តដែលមានភាពរីកចំរើនរបស់បទដ្ឋានស្នូល និងបន្តការកែលម្អឱ្យប្រសើរឡើង
- តាមដានគុណភាព និងគណនេយ្យភាពតាមរយៈការប្រើបទដ្ឋានស្នូលមនុស្សធម៌ជាក្របខ័ណ្ឌមួយ ដើម្បីគាំទ្របទដ្ឋានរបស់អង្គការ និងបទដ្ឋានបច្ចេកទេសដែលមានស្រាប់

- វាយតម្លៃខ្លួនឯង និងការកែលម្អគុណភាពរបស់កម្មវិធី
- ផ្ទៀងផ្ទាត់ ឬបញ្ជាក់អនុលោម និងដើម្បីបង្ហាញពីការគោរពតាមបទដ្ឋានដល់អ្នកដទៃ
- ការវាយតម្លៃកន្លែងដែលពាក់ព័ន្ធ ថាតើវាឆ្ងាយពីគ្នាបែបណារវាងដំណើរការខាងក្នុង និងការគាំទ្របុគ្គលិកដើម្បីបំពេញសកម្មភាពគន្លឹះ ហើយនិងការទទួលខុសត្រូវរបស់អង្គការដែលបានកំណត់នៅក្នុងបទដ្ឋានស្នូលមនុស្សធម៌។

អង្គការដែលបានសម្រេចចិត្តក្នុងការប្រើប្រាស់បទដ្ឋានស្នូលមនុស្សធម៌គួរលើកកម្ពស់វាទាំងក្នុងអង្គការរបស់ខ្លួននិងខាងក្រៅ។

អង្គការដែលអនុវត្តការងារក្នុងភាពជាដៃគូ គួរពន្យល់ពីការប្តេជ្ញាចំពោះបទដ្ឋានស្នូលមនុស្សធម៌ ស្វែងយល់ពីរបៀបដែលដៃគូ[3] ប្រើប្រាស់សម្រាប់ការប្តេជ្ញាទាំង ៩ និងធ្វើអ្វីដែលពួកគេអាចធ្វើទៅបានជាមួយការអនុវត្តការប្តេជ្ញារបស់បទដ្ឋានស្នូលមនុស្សធម៌។

## ៤. អំណះអំណាង

បុគ្គល ឬអង្គការណាក៏ដោយដែលធ្វើការទាក់ទងនឹងសកម្មភាពមនុស្សធម៌ គឺត្រូវបានលើកទឹកចិត្តក្នុងការប្រើប្រាស់ និងបន្សាំទៅនឹងបទដ្ឋានស្នូលមនុស្សធម៌ និងអាចបញ្ជាក់បានថា "យើងកំពុងធ្វើការឆ្ពោះទៅរកវាល់កម្មវិធីរបស់បទដ្ឋានស្នូលមនុស្សធម៌"។ អង្គការអាចត្រឹមតែអះអាងថាពួកគេគោរពតាមបទដ្ឋានស្នូលមនុស្សធម៌ ប្រសិនបើពួកគេបានទទួលការផ្ទៀងផ្ទាត់គោលបំណងជាមួយនឹងវា។

[3] សូមមើលនិយមន័យក្នុងសទ្ទានុក្រម

## ៥. គោលការណ៍សកម្មភាពមនុស្សធម៌

មនុស្សជាតិជាបេះដូងនៃសកម្មភាពមនុស្សធម៌។ ការលើកទឹកចិត្តជាចម្បងនៃការឆ្លើយតបទៅនឹងវិបត្តិ គឺជាការសង្គ្រោះជីវិតមនុស្ស កាត់បន្ថយទុក្ខវេទនារបស់មនុស្ស និងដើម្បីគាំទ្រសិទ្ធិរស់រានមានជីវិតប្រកបដោយភាពថ្លៃថ្នូរ។

អង្គការមនុស្សធម៌ទទួលស្គាល់ថា ភាពចាំបាច់នៃជំនួយមនុស្សធម៌មកមុន ហើយការស្វែងរកដូច្នេះដើម្បីផ្តល់ជំនួយមនុស្សធម៌នៅគ្រប់ទីកន្លែងដែលត្រូវការ។

សកម្មភាពមនុស្សធម៌ គឺត្រូវបានណែនាំដោយគោលការណ៍[4] ធំៗចំនួនបួនដែលទទួលស្គាល់យ៉ាងទូលំទូលាយ៖

- **មនុស្សជាតិ៖** ភាពរងទុក្ខវេទនារបស់មនុស្សជាតិត្រូវបានដោះស្រាយគ្រប់កន្លែងដែលរកឃើញ។ គោលបំណងនៃសកម្មភាពមនុស្សធម៌ គឺដើម្បីការពារអាយុជីវិត និងសុខភាព ហើយធានាបាននូវការគោរពភាពជាមនុស្ស។
- **ភាពមិនលំអៀង៖** សកម្មភាពមនុស្សធម៌ត្រូវតែអនុវត្តដោយផ្អែកលើមូលដ្ឋានតម្រូវការតែមួយគត់ ការផ្តល់អាទិភាពដល់ករណីបន្ទាន់បំផុតនៃទុក្ខវេទនា និងការអនុវត្តមិនឱ្យមានភាពខុសគ្នាលើមូលដ្ឋាននៃសញ្ជាតិ ពូជសាសន៍ ភេទ ជំនឿ សាសនា វណ្ណៈ ឬគោលនយោបាយ។
- **ឯករាជ្យភាព៖** សកម្មភាពមនុស្សធម៌ត្រូវតែស្វ័យតពីនយោបាយ សេដ្ឋកិច្ច យោធា ឬ វត្ថុបំណងដទៃទៀតគឺ ដើម្បីឱ្យអ្នកប្រើប្រាស់បទដ្ឋាននេះអាចអនុវត្តបាននៅគ្រប់កន្លែងដែលមានសកម្មភាពមនុស្សធម៌។
- **អព្យាក្រិត្យភាព៖** ភ្នាក់ងារមនុស្សធម៌ដាច់ខាតមិនត្រូវស្ថិតក្នុងអរិភាព ឬចូលរួមនៃភាពចម្រូងចម្រាសក្នុងការងារនយោបាយ ពូជសាសន៍ សាសនា ឬមនោគមវិជ្ជាណាមួយឡើយ។[5]

គោលការណ៍មនុស្សធម៌ គឺជាចំនុចស្នូលនៃការងារមនុស្សធម៌ទាំងអស់។ ពួកវាបានណែនាំសកម្មភាពមនុស្សធម៌ ហើយកម្មវិធីទាំងនោះ គឺមានសារៈសំខាន់ដើម្បីសម្គាល់សកម្មភាពមនុស្សធម៌ចេញពីទម្រង់ផ្សេងៗគ្នានៃសកម្មភាពនិងការអនុវត្ត។ បទដ្ឋានស្នូលមានគោលការណ៍ចំនួន៤ត្រូវបានដាក់បញ្ចូល គឺការប្តេជ្ញាចិត្ត លក្ខណៈវិនិច្ឆ័យគុណភាព សកម្មភាពគន្លឹះ និងការទទួលខុសត្រូវរបស់អង្គការ។

[4] គោលការណ៍ មនុស្សជាតិ ភាពមិនលំអៀង ឯករាជ្យភាព និងអព្យាក្រិត្យភាពយកចេញពី៖ គោលការណ៍គ្រឹះនៃចលនា កាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិបានប្រកាសនៅក្រុងវីយ៉ែនក្នុងឆ្នាំ 1965 នៅសន្និសិទ្ធអន្តរជាតិលើកទី 20 មហាសន្និបាតអង្គការសហប្រជាជាតិ 46/182 ថ្ងៃទី19 ខែធ្នូឆ្នាំ1991 និងមហាសន្និបាតអង្គការសហប្រជាជាតិ 58/114 ថ្ងៃទី 5 ខែកុម្ភៈឆ្នាំ 2004 ។

[5] ខណៈពេលផ្តល់ជំនួយដោយមិនលំអៀង និង មិនទទួលយកភាគីមួយនៅក្នុងអរិភាព អង្គការមួយចំនួនមិនបានពិចារណា ដែលខកខានមិនទទួលយកគោលការណ៍អព្យាក្រឹតភាព ការតស៊ូមតិលើបញ្ហាដែលទាក់ទងទៅនឹងគណនេយ្យភាពនិងយុត្តិធម៌។

ច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជនភៀសខ្លួនអន្តរជាតិបានកំណត់ជាមូលដ្ឋានបទដ្ឋានស្របច្បាប់ទាក់ទងទៅនឹងការការពាររបស់បគ្គល និងក្រុមព្រមទាំងជំនួយផ្សេងៗដែលអាចត្រូវបានផ្ដល់ទៅឱ្យពួកគេ។ ធម្មនុញ្ញមនុស្សធម៌ក្នុងសៀវភៅស្ហ្វៀរបានសង្ខេបគោលការណ៍ស្នូលដែលមានឥទ្ធិពលច្រើនជាងគេបំផុតនៅលើសុខុមាលភាពនៃជនរងគ្រោះដោយគ្រោះមហន្តរាយឬជម្លោះ។

រាល់អ្នកដែលអនុវត្តបទដ្ឋានស្នូលមនុស្សធម៌ ទទួលស្គាល់ការទទួលខុសត្រូវជាចម្បងនៃបណ្ដារដ្ឋ និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀតដើម្បីការពារ និងជួយដល់អ្នកទាំងឡាយណាដែលរងគ្រោះដោយគ្រោះមហន្តរាយ ឬជម្លោះប្រដាប់អាវុធនៅក្នុងទឹកដីរបស់ពួកគេ។ សកម្មភាពមនុស្សធម៌ មិនគួរធ្វើឱ្យប៉ះពាល់ដលការទទួលខុសត្រូវរបស់ពួកគេឡើយ ហើយវាតែងបំពេញឱ្យគ្នាទៅវិញទៅមកនៅពេលណាដែលអាចធ្វើបាន។

# ៦. ការប្តេជ្ញាចិត្ត ៩ និងលក្ខណៈវិនិច្ឆ័យគុណភាព

១. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយយ៉ាងសមរម្យ និងសមស្របទៅនឹងសេចក្តីត្រូវការរបស់ពួកគេ។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ការឆ្លើយតបជំនួយមនុស្សធម៌សមរម្យ និងសមស្រប។

២. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយមនុស្សធម៌ដែលពួកគេត្រូវការទាន់ពេលវេលា។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ការឆ្លើយតបជំនួយមនុស្សធម៌មានប្រសិទ្ធិភាព និងទាន់ពេលវេលា

៣. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយមិនរងគ្រោះកាន់តែធ្ងន់ធ្ងរថែមទៀត ប៉ុន្តែគេកាន់តែត្រៀមបានល្អ ធន់ និងមានហានិភ័យទាបដែលជាលទ្ធផលនៃជំនួយមនុស្សធម៌។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ការឆ្លើយតបជំនួយមនុស្សធម៌ពង្រឹងសមត្ថភាពប្រជាជនមូលដ្ឋាន និងបញ្ចៀសលទ្ធផលជាអវិជ្ជមានផ្សេងៗ។

៤. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយយល់ដឹងអំពីសិទ្ធិរបស់ពួកគេ និងដឹងអ្វីដែលគេត្រូវទទួលបាន និងអាចទទួលបានព័ត៌មាន ព្រមទាំងអាចចូលរួមក្នុងការសម្រេចចិត្តលើការងារដែលពាក់ព័ន្ធនឹងពួកគេ។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ការឆ្លើយតបជំនួយមនុស្សធម៌គឺផ្អែកលើការទំនាក់ទំនង ការចូលរួម និងការទទួលមតិយោបល់ឆ្លុះបញ្ចាំង។

៥. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានយន្តការដោះស្រាយបណ្តឹងតវ៉ាទាន់ពេលវេលា និងប្រកបដោយសុវត្ថិភាព។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** បណ្តឹងតវ៉ាត្រូវបានទទួលការស្វាគមន៍ និងដោះស្រាយ។

៦. សហគមន៍និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយ ដែលមានកិច្ចសហប្រតិបត្តិការ និងបំពេញបន្ថែម។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ជំនួយមនុស្សធម៌ដែលមានកិច្ចសហប្រតិបត្តិការ និងបំពេញបន្ថែម។

៧. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយអាចរំពឹងថា បានទទួលជំនួយដែលមានការកែលម្អ ពីព្រោះអង្គការបានរៀនសូត្រពីបទពិសោធន៍ និងការឆ្លុះបញ្ចាំង។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ភ្នាក់ងារជំនួយមនុស្សធម៌បន្តរៀនសូត្រ និងកែលម្អ។

៨. សហគមន៍ និងជនរងដោយគ្រោះមហន្តរាយទទួលបានជំនួយដែលពួកគេត្រូវការពីភ្នាក់ងារ និងអ្នកស្ម័គ្រចិត្តដែលមានសមត្ថភាពត្រឹមត្រូវ និងគ្រប់គ្រងបានល្អ។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** បុគ្គលិកបានទទួលការគាំទ្រដើម្បីធ្វើការងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធិភាពនិងទទួលបានការឧបត្ថម្ភសមស្រប និងមានសមភាព។

## ៩. សហគមន៍ និងជនដែលរងគ្រោះដោយគ្រោះមហន្តរាយអាចរំពឹងថាអង្គការដែលជួយពួកគេមានការគ្រប់គ្រងធនធានដ៏មានប្រសិទ្ធិភាពត្រឹមត្រូវ និងប្រកបដោយក្រមសីលធម៌។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ធនធានត្រូវបានប្រើប្រាស់ និងគ្រប់គ្រងបានត្រឹមត្រូវប្រកបដោយការទទួលខុសត្រូវទៅតាមគោលបំណងដែលគេចង់បាន។

# ៧. ការប្តេជ្ញា សកម្មភាពគន្លឹះ និងការទទួលខុសត្រូវ

## ១. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយយ៉ាងសមរម្យ និងសមស្របទៅនឹងសេចក្តីត្រូវការរបស់ពួកគេ

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ការឆ្លើយតបជំនួយមនុស្សធម៌សមរម្យ និងសមស្រប។

**សកម្មភាពគន្លឹះ**

១.១ អនុវត្តជាប្រព័ន្ធតាមរយៈគោលដៅ និងការបន្តវិភាគបរិបទ និងភាគីដែលពាក់ព័ន្ធ។

១.២ បង្កើត និងអនុវត្តគម្រោងដែលសមស្របដោយផ្អែកលើការប៉ាន់ប្រមាណមិនលំអៀងមួយពីតម្រូវការ[6] និងហានិភ័យ ព្រមទាំងការស្វែងយល់ពីភាពងាយរងគ្រោះ និងសមត្ថភាពនៃក្រុមផ្សេងៗគ្នា។[7]

១.៣ សម្របតាមកម្មវិធីដោយផ្លាស់ប្តូរអាស្រ័យទៅនឹងតម្រូវការសមត្ថភាព និងបរិបទ។

**ការទទួលខុសត្រូវរបស់អង្គការ**

១.៤ គោលនយោបាយមានការប្តេជ្ញាចិត្ត ដើម្បីផ្តល់ជំនួយមនុស្សធម៌ដោយផ្អែកលើតម្រូវការ និងសមត្ថភាពសហគមន៍និងជនរងគ្រោះដោយគ្រោះមហន្តរាយ។

១.៥ គោលនយោបាយកំណត់ពីការប្តេជ្ញាចិត្ត ដែលមានគណនេយ្យភាពចំពោះភាពចម្រុះនៃសហគមន៍រួមទាំងប្រជាជនដែលជួបការលំបាក ឬបាត់បង់ឱកាស និងដើម្បីប្រមូលទិន្នន័យលម្អិតពីសហគមន៍។

១.៦ មានដំណើរការ ដើម្បីធានាបាននូវការបន្តការវិភាគមួយដែលសមរម្យទៅនឹងបរិបទ។

[6] តម្រូវការគឺរួមបញ្ចូលទាំងជំនួយ និងការការពារ

[7] វាអាចសំដៅលើ៖ស្ត្រី បុរស កុមារី កុមារា យុវជន និងមនុស្សចាស់ ក៏ដូចជាជនពិការ និងជនជាតិភាគតិចជាក់លាក់ ឬក្រុមជនជាតិដើមភាគតិច ដោយគ្មានការរើសអើង

## ២. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយមនុស្សធម៌ដែលពួកគេត្រូវការទាន់ពេលវេលា

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ការឆ្លើយតបជំនួយមនុស្សធម៌មានប្រសិទ្ធិភាព និងទាន់ពេលវេលា

**សកម្មភាពគន្លឹះ**

២.១ បង្កើតកម្មវិធីដែលដោះស្រាយឧបសគ្គនានា ដូច្នេះសកម្មភាពដែលបានស្នើឡើងមានភាពជាក់លាក់ និងមានសុវត្ថិភាពសម្រាប់សហគមន៍។

២.២ ផ្តល់ការឆ្លើយតបជំនួយមនុស្សធម៌ទាន់ពេលវេលា ដោយធ្វើការសម្រេចចិត្ត និងអនុវត្តដោយមិនពន្យាពេលដែលមិនចាំបាច់។

២.៣ ណែនាំទៅដល់អង្គការទាំងឡាយ ពីសេចក្តីត្រូវការដែលមិនបានបំពេញ ជាមួយនឹងជំនាញបច្ចេកទេសដែលពាក់ព័ន្ធនិងអាណត្តិ ឬការតស៊ូមតិសម្រាប់ការដោះស្រាយតម្រូវការ។

២.៤ ប្រើបទដ្ឋានបច្ចេកទេសដែលពាក់ព័ន្ធ និងការអនុវត្តល្អនៅទូទាំងវិស័យមនុស្សធម៌ក្នុងការធ្វើផែនការនិងប៉ាន់ប្រមាណកម្មវិធី។

២.៥ ត្រួតពិនិត្យសកម្មភាព ទិន្នផល និងលទ្ធផលនៃការឆ្លើយតបជំនួយមនុស្សធម៌ ដើម្បីសម្របតាមកម្មវិធីឱ្យបានប្រសើរឡើង និងដោះស្រាយការអនុវត្តដែលមិនល្អ។

**ការទទួលខុសត្រូវរបស់អង្គការ**

២.៦ ការប្តេជ្ញាចិត្តរបស់កម្មវិធី គឺវាស្របគ្នាជាមួយនឹងសមត្ថភាពរបស់អង្គភាព។

២.៧ ការប្តេជ្ញារបស់គោលនយោបាយធានាបាននូវ៖

ក. រៀបចំជាប្រព័ន្ធពីគោលបំណង និងបន្តការត្រួតពិនិត្យ និងការវាយតម្លៃលើសកម្មភាព និងផលប៉ះពាល់របស់វា

ខ. ប្រើប្រាស់ភស្តុតាងដែលបានមកពីការត្រួតពិនិត្យ និងការវាយតំលៃ ដើម្បីកែសម្រួល និងកែលម្អកម្មវិធីឱ្យប្រសើរឡើង

គ. សម្រេចចិត្តទាន់ពេលវេលាជាមួយនឹងធនធានដែលបានបម្រុងទុករួចជាស្រេច។

## ៣. សហគមន៍និងជនរងគ្រោះដោយគ្រោះមហន្តរាយមិនរងគ្រោះកាន់តែធ្ងន់ថែមទៀត ប៉ុន្តែគេកាន់តែ ត្រៀមបានល្អ ធន់ និងមានហានិភ័យទាបដែលជាលទ្ធផលនៃជំនួយមនុស្សធម៌

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ការឆ្លើយតបជំនួយមនុស្សធម៌ពង្រឹងសមត្ថភាពប្រជាជនមូលដ្ឋាន និងបញ្ចៀសលទ្ធផលអវិជ្ជមានផ្សេងៗ។

**សកម្មភាពគន្លឹះ**

៣.១ ធានាថារៀបចំកម្មវិធីដោយផ្អែកលើសមត្ថភាពតាមមូលដ្ឋាន និងធ្វើការឆ្ពោះទៅរកការលើកកម្ពស់ភាពធន់របស់សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ។

៣.២ ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃមុខសញ្ញាគ្រោះថ្នាក់ និងការប៉ាន់ប្រមាណហានិភ័យរបស់សហគមន៍ដែលមានស្រាប់ និងផែនការត្រៀមបង្ការសម្រាប់ការរៀបចំផែនការសកម្មភាព។

៣.៣ជំរុញឱ្យមានការអភិវឌ្ឍភាពជាអ្នកដឹកនាំនៅតាមមូលដ្ឋាន និងអង្គការពីសមត្ថភាពនៃការឆ្លើយតបមុនគេទៅនឹងគ្រោះមហន្តរាយដែលកើតឡើងនាពេលខាងមុខដោយធានាថាក្រុមជនជាតិភាគតិច និងក្រុមជនងាយរងគ្រោះមានអ្នកតំណាងយ៉ាងសមរម្យ។

៣.៤ រៀបចំផែនការយុទ្ធសាស្រ្តអន្តរកាល ឬផែនការបញ្ចប់គម្រោងតាំងពីដំណាក់កាលចាប់ផ្តើមដំបូងនៃកម្មវិធីជំនួយមនុស្សធម៌ដែលធានាពីលទ្ធផលជាវិជ្ជមានរយៈពេលវែង និងកាត់បន្ថយហានិភ័យនៃភាពពឹងអាស្រ័យ។

៣.៥ រៀបចំ និងអនុវត្តកម្មវិធីដែលជំរុញការស្តារឡើងវិញពីគ្រោះមហន្តរាយ និងផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចក្នុងតំបន់។

៣.៦ កំណត់ និងអនុវត្ត អាស្រ័យលើសក្តានុពល ឬផលប៉ះពាល់អវិជ្ជមានដែលមិនចង់បានឱ្យទាន់ពេលវេលា និងជាលក្ខណៈប្រព័ន្ធ ដោយពិចារណាលើចំណុចមួយចំនួនដូចជា៖

**ក.** សុវត្ថិភាព សន្តិសុខ សេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់ប្រជាជន

**ខ.** ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទពីបុគ្គលិកជំនួយមនុស្សធម៌

**គ.** វប្បធម៌ យេនឌ័រ និងទំនាក់ទំនងសង្គមនិងនយោបាយ

**ឃ.** ជីវភាពរស់នៅ

**ង.** សេដ្ឋកិច្ចក្នុងតំបន់ និង

**ច.** បរិស្ថាន

## ការទទួលខុសត្រូវរបស់អង្គការ

៣.៧ គោលនយោបាយ យុទ្ធសាស្ត្រ និងការណែនាំ ត្រូវបានបង្កើតឡើងដើម្បី៖

**ក.** ទប់ស្កាត់កម្មវិធីដែលមានផលប៉ះពាល់ជាអវិជ្ជមានណាមួយ ដូចជាការកេងប្រវ័ញ្ច ការរំលោភបំពាន ឬការរើសអើងដោយបុគ្គលិកទៅលើសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ។

**ខ.** ពង្រឹងសមត្ថភាពក្នុងមូលដ្ឋាន។

៣.៨ មានប្រព័ន្ធ ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនដែលប្រមូលពីសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ ដែលអាចធ្វើឱ្យពួកគេស្ថិតក្នុងហានិភ័យ។

## ៤.សហគមន៍និងជនរងគ្រោះដោយគ្រោះមហន្តរាយយល់ដឹងអំពីសិទ្ធិរបស់ពួកគេនិងដឹងអ្វីដែលគេត្រូវទទួលបាននិងអាចទទួលបានព័ត៌មាន ព្រមទាំងអាចចូលរួមក្នុងការសម្រេចចិត្តលើការងារដែលពាក់ព័ន្ធនឹងពួកគេ។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ការឆ្លើយតបជំនួយមនុស្សធម៌ គឺផ្អែកលើទំនាក់ទំនងការចូលរួម និងការទទួលមតិយោបល់ឆ្លុះបញ្ចាំង។

**សកម្មភាពគន្លឹះ**

៤.១ ផ្តល់ព័ត៌មានដល់សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយអំពីអង្គការក្រមសីលធម៌ដែលគេប្រកាន់យកការរំពឹងទុកពីអាកប្បកិរិយារបស់បុគ្គលិក កម្មវិធីដែលកំពុងអនុវត្ត និងអ្វីដែលពួកគេចង់ផ្តល់ឱ្យសហគមន៍។

៤.២ ប្រាស្រ័យទាក់ទងជាភាសា ជាទម្រង់ និងប្រព័ន្ធផ្សព្វផ្សាយដែលងាយស្រួលយល់ប្រកបដោយការគោរព និងសមស្របទៅនឹងវប្បធម៌សម្រាប់គ្រប់ៗគ្នានៅក្នុងសហគមន៍ជាពិសេសក្រុមដែលងាយរងគ្រោះ និងក្រុមជនជាតិភាគតិច។

៤.៣ ធានាថាមានតំណាងចម្រុះពីសហគមន៍ ដោយមានការចូលរួម និងទំនាក់ទំនងពីសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយនៅគ្រប់ដំណាក់កាលទាំងអស់នៃការងារ។

៤.៤ លើកទឹកចិត្តនិងសម្របសម្រួលដល់សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយដើម្បីផ្តល់នូវមតិត្រឡប់ពីកម្រិតលើ ការពេញចិត្តរបស់ពួកគេជាមួយនឹងគុណភាព និងប្រសិទ្ធភាពនៃជំនួយដែលពួកគេបានទទួលផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅតាមអាយុ ភេទ និងភាពចម្រុះនៃអ្នកផ្តល់មតិត្រឡប់។

**ការទទួលខុសត្រូវរបស់អង្គការ**

៤.៥ មានគោលនយោបាយសម្រាប់ការចែករំលែកព័ត៌មាន និងជំរុញវប្បធម៌បើកចំហនៃទំនាក់ទំនង

៤.៦ មានគោលនយោបាយសម្រាប់ធ្វើការជាមួយសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ ដោយឆ្លុះបញ្ចាំងពីអាទិភាព និងហានិភ័យដែលពួកគេបានកំណត់នៅក្នុងគ្រប់ដំណាក់កាលនៃការងារជំនួយសង្គ្រោះ។

៤.៧ ទំនាក់ទំនងខាងក្រៅ រួមទាំងទំនាក់ទំនងក្នុង គោលបំណងកៀរគរមូលនិធិត្រូវមានលក្ខណៈច្បាស់លាស់ត្រឹមត្រូវមានក្រមសីលធម៌ និងប្រកបដោយការគោរព ដែលតំណាងឱ្យសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយក្នុងភាពថ្លៃថ្នូរជាមនុស្សជាតិ។

## ៥. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានយន្តការដោះស្រាយបណ្ដឹងតវ៉ាទាន់ពេលវេលា និងប្រកបដោយសុវត្ថិភាព។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** បណ្ដឹងតវ៉ាត្រូវបានទទួលការស្វាគមន៍ និងដោះស្រាយ។

**សកម្មភាពគន្លឹះ**

៥.១ ពិគ្រោះយោបល់ជាមួយសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយក្នុងការរៀបចំ អនុវត្ត និងត្រួតពិនិត្យដំណើរការដោះស្រាយបណ្ដឹងតវ៉ា។

៥.២ ស្វាគមន៍និងទទួលបណ្ដឹងតវ៉ា និងប្រាប់អំពីរបៀបដែលអាចទទួលបានយន្តការនេះ និងវិសាលភាពនៃបញ្ហាដែលអាចដោះស្រាយបាន។

៥.៣ គ្រប់គ្រង និងចាត់ចែងបណ្ដឹងតវ៉ាទាំងនោះឱ្យទាន់ពេលវេលាប្រកបដោយយុត្តិធម៌ និងសមស្រប។ ផ្ដល់អាទិភាពចំពោះសុវត្ថិភាពនៃបណ្ដឹងតវ៉ា និងជនរងគ្រោះដោយគ្រោះមហន្តរាយនៅក្នុងគ្រប់ដំណាក់កាលទាំងអស់។

**ការទទួលខុសត្រូវរបស់អង្គការ**

៥.៤ ដំណើរការដោះស្រាយបណ្ដឹងតវ៉ាសម្រាប់សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយត្រូវបានចងក្រងជាឯកសារ និងរក្សាទុកយ៉ាងរៀបរយ។ ដំណើរការគួរត្រូវគ្របដណ្ដប់លើកម្មវិធីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ និងបំពានពីការប្រើប្រាស់អំណាច។

៥.៥ បង្កើត និងរៀបចំវប្បធម៌របស់អង្គការដែលក្នុងនោះបណ្ដឹងតវ៉ាត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង និងអនុវត្តដោយផ្អែកលើគោលនយោបាយ និងដំណើរការដែលបានកំណត់។

៥.៦ សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយដឹងយ៉ាងច្បាស់ពីឥរិយាបថរំពឹងទុករបស់បុគ្គលិកមនុស្សធម៌ រួមបញ្ចូលទាំងការប្ដេជ្ញាចិត្តរបស់អង្គការក្នុងការការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។

៥.៧ បណ្ដឹងតវ៉ាដែលមិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់ស្ថាប័ន ត្រូវបញ្ជូនទៅឱ្យអ្នកពាក់ព័ន្ធដោយអនុលោមទៅនឹងការអនុវត្តល្អ។

## ៦. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ ទទួលបានជំនួយ ដែលមានកិច្ចសហប្រតិបត្តិការនិងបំពេញបន្ថែម។

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ជំនួយមនុស្សធម៌ដែលមានកិច្ចសហប្រតិបត្តិការ និងបំពេញបន្ថែម។

**សកម្មភាពគន្លឹះ**

៦.១ កំណត់ តួនាទី ការទទួលខុសត្រូវ សមត្ថភាព និងចំណង់ចំណូលចិត្តនៃគ្រប់ភាគីពាក់ព័ន្ធ។[8]

៦.២ ធានាថាការឆ្លើយតបជំនួយមនុស្សធម៌បំពេញបន្ថែម ទៅលើជំនួយមនុស្សធម៌របស់អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន[9] និងអង្គការមនុស្សធម៌ដទៃផ្សេងទៀត។

៦.៣ ចូលរួមក្នុងគណៈកម្មការសម្របសម្រួលដែលពាក់ព័ន្ធ និងសហការជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីកាត់បន្ថយតម្រូវការសម្រាប់សហគមន៍ និងបង្កើនការគ្របដណ្តប់ និងផ្តល់សេវាកម្មជំនួយមនុស្សធម៌ឱ្យកាន់តែទូលំទូលាយ។

៦.៤ ចែករំលែកព័ត៌មានចាំបាច់ជាមួយដៃគូ ក្រុមសម្របសម្រួល និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមរយបណ្តាញទំនាក់ទំនងដែលសមស្រប។

**ការទទួលខុសត្រូវរបស់អង្គការ**

៦.៥ គោលនយោបាយ និងយុទ្ធសាស្ត្រ រួមបញ្ចូលការប្តេជ្ញាច្បាស់លាស់ក្នុងការសម្របសម្រួល និងសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត ដូចជាអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដោយគ្មានការលើកលែងចំពោះគោលការណ៍ជំនួយមនុស្សធម៌។

៦.៦ ធ្វើការជាមួយដៃគូ ត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងច្បាស់លាស់និងស៊ីគ្នា និងគោរពអាណត្តិ កាតព្វកិច្ច និងឯករាជ្យភាពគ្នាទៅវិញទៅមក និងទទួលស្គាល់ឧបសគ្គ និងការប្តេជ្ញាចិត្តរបស់ពួកគេ។

[8] រួមបញ្ចូលអាជ្ញាធរមូលដ្ឋាន អង្គការមនុស្សធម៌ ក្រុមហ៊ុនឯកជន និងក្រុមដែលពាក់ព័ន្ធផ្សេងៗទៀត

[9] កន្លែងណាដែលអាជ្ញាធរគឺជាភាគីជម្លោះភ្នាក់ងារមនុស្សធម៌គួរប្រើការវិនិច្ឆ័យដោយឯករាជ្យភាព រក្សាការយកចិត្តទុកដាក់ចំពោះសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយដោយយកពួកគេជាចំណុចកណ្តាលក្នុងការធ្វើសេចក្តីសម្រេច

## ៧. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយអាចរំពឹងថាបានទទួលជំនួយដែលមានការកែលម្អពីព្រោះអង្គការបានរៀនសូត្រពីបទពិសោធន៍ និងការឆ្លុះបញ្ចាំង

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ភ្នាក់ងារជំនួយមនុស្សធម៌បន្តរៀនសូត្រ និងកែលម្អ។

**សកម្មភាពគន្លឹះ**

៧.១ រៀនសូត្រពីមេរៀនទទួលបាន និងបទពិសោធន៍ នៅពេលរៀបចំកម្មវិធី។

៧.២ រៀនសូត្រ ច្នៃប្រឌិត និងអនុវត្តការផ្លាស់ប្តូរដោយផ្អែកលើការត្រួតពិនិត្យ ការវាយតម្លៃ និងមតិត្រឡប់ ព្រមទាំងបណ្តឹងតវ៉ា។

៧.៣ ចែករំលែកការរៀនសូត្រ និងការច្នៃប្រឌិតទាំងក្នុងស្ថាប័ន ជាមួយសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយនិងភាគីពាក់ព័ន្ធដទៃទៀត។

**ការទទួលខុសត្រូវរបស់អង្គការ**

៧.៤ មានគោលនយោបាយវាយតម្លៃ និងរៀនសូត្រ និងមានយន្តការ ដើម្បីរៀនសូត្រពីបទពិសោធន៍ និងកែលម្អការអនុវត្ត។

៧.៥ មានយន្តការ ក្នុងការកត់ត្រាចំណេះដឹង និងបទពិសោធន៍ និងអាចរកបានយ៉ាងទូលំទូលាយក្នុងស្ថាប័ន។

៧.៦ អង្គការចូលរួមចំណែកដល់ការរៀនសូត្រ និងគំនិតថ្មីក្នុងការឆ្លើយតបជំនួយមនុស្សធម៌ក្នុងចំណោមមិត្តរួមការងារ និងក្នុងវិស័យជំនួយមនុស្សធម៌។

## ៨. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយទទួលបានជំនួយដែលពួកគេត្រូវការ ពីភ្នាក់ងារ និងអ្នកស្ម័គ្រចិត្តដែលមានសមត្ថភាពត្រឹមត្រូវ និងគ្រប់គ្រងបានល្អ

**លក្ខណៈវិនិច្ឆ័យគុណភាព៖** បុគ្គលិក[10] បានទទួលការគាំទ្រដើម្បីធ្វើការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងទទួលបានការឧបត្ថម្ភសមស្រប និងមានសមភាព។

**សកម្មភាពគន្លឹះ**

៨.១ បុគ្គលិកធ្វើការដោយផ្អែកលើអាណត្តិ និងគុណតម្លៃរបស់ស្ថាប័ន និងទៅលើវត្ថុបំណងដែលបានព្រមព្រៀងគ្នា និងបទដ្ឋាននៃការអនុវត្តការងារ។

៨.២ បុគ្គលិកប្រកាន់ខ្ជាប់នូវគោលនយោបាយដែលមានការពាក់ព័ន្ធ និងយល់ដឹងពីផលវិបាកនៃការមិនប្រកាន់ខ្ជាប់ទៅនឹងគោលនយោបាយទាំងនោះ។

៨.៣ បុគ្គលិកអភិវឌ្ឍនឹងប្រើប្រាស់សមត្ថភាពគ្រប់គ្រងបច្ចេកទេស និងសមត្ថភាពផ្ទាល់ខ្លួនដែលចាំបាច់ដើម្បីបំពេញតួនាទីរបស់ខ្លួន និងយល់ដឹងពីរបៀបដែលអង្គការអាចគាំទ្រពួកគេ ដើម្បីធ្វើការទាំងអស់នោះ។

**ការទទួលខុសត្រូវរបស់អង្គការ**

៨.៤ អង្គការមានសមត្ថភាពផ្នែកគ្រប់គ្រង និងបុគ្គលិក ក្នុងការអនុវត្តកម្មវិធីនោះ។

៨.៥ គោលនយោបាយ និងនីតិវិធីបុគ្គលិក មានយុត្តិធម៌ តម្លាភាព និងមិនរើសអើង និងស្របតាមច្បាប់ការងារក្នុងស្រុក។

៨.៦ មានការពិពណ៌នាការងារ គោលបំណងការងារ និងដំណើរការផ្តល់មតិត្រឡប់ ដូច្នេះបុគ្គលិកយល់ច្បាស់ពីអ្វីដែលជាតម្រូវការសម្រាប់បំពេញការងារនេះ។

៨.៧ មានក្រមសីលធម៌ ដែលយ៉ាងហោចណាស់បង្កើតកាតព្វកិច្ចដល់បុគ្គលិកមិនឱ្យមានការកេងប្រវ័ញ្ចការរំលោភបំពាន ឬរើសអើងប្រឆាំងនឹងមនុស្សជាតិ។

៨.៨ មានគោលនយោបាយ ដើម្បីគាំទ្រដល់បុគ្គលិកក្នុងការបង្កើនជំនាញ និងសមត្ថភាពរបស់ពួកគេ។

៨.៩ មានគោលនយោបាយសម្រាប់សន្តិសុខ និងសុខុមាលភាពរបស់បុគ្គលិក។

[10] បុគ្គលិកជាអ្នកតំណាងរបស់អង្គការគិតរួមបញ្ចូលបុគ្គលិកជាតិ អន្តរជាតិ និងអចិន្ត្រៃយ៍ ឬរយៈពេលខ្លី ក៏ដូចជាអ្នកស្ម័គ្រចិត្ត និងទីប្រឹក្សាផងដែរ

## ៩. សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយអាចរំពឹងថាអង្គការដែលជួយពួកគេមានការគ្រប់គ្រងធនធានដ៏មានប្រសិទ្ធភាពត្រឹមត្រូវ និងប្រកបដោយក្រមសីលធម៌

**លក្ខណៈវិនិច្ឆ័យគុណភាព៖** ធនធានត្រូវបានប្រើប្រាស់ និងគ្រប់គ្រងបានត្រឹមត្រូវប្រកបដោយការទទួលខុសត្រូវទៅតាមគោលបំណងដែលគេចង់បាន។

**សកម្មភាពគន្លឹះ**

៩.១ បង្កើតកម្មវិធី និងដំណើរការអនុវត្ត ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន[11] ដោយរក្សាតុល្យភាពគុណភាពប្រសិទ្ធភាពនៃការចំណាយ និងពេលវេលានៅរាល់ដំណាក់កាលនៃការឆ្លើយតប។

៩.២ ចាត់ចែង និងប្រើប្រាស់ធនធានដើម្បីសម្រេចបាននូវគោលបំណងកាត់បន្ថយភាពខ្ជះខ្ជាយ។

៩.៣ ត្រួតពិនិត្យ និងរាយការណ៍រាល់ការចំណាយធៀបនឹងផែនការថវិកា។

៩.៤ ពិចារណាពីផលប៉ះពាល់លើបរិស្ថាននៅពេលប្រើធនធានក្នុងស្រុក និងធនធានធម្មជាតិ។

៩.៥ គ្រប់គ្រងហានិភ័យនៃអំពើពុករលួយ និងចាត់វិធានការសមស្របប្រសិនបើរកឃើញ

**ការទទួលខុសត្រូវរបស់អង្គការ**

៩.៦ មានគោលនយោបាយ និងដំណើរការដែលគ្រប់គ្រងការប្រើប្រាស់ និងគ្រប់គ្រងធនធានរួមមានរបៀបដែលអង្គការ៖

**ក.** ទទួលយកនិងការបែងចែកមូលនិធិ និងអំណោយមិនមែនហិរញ្ញវត្ថុប្រកបដោយក្រមសីលធម៌និងស្របច្បាប់

**ខ.** ប្រើធនធានរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវចំពោះបរិស្ថាន

**គ.** បង្ការ និងដោះស្រាយបញ្ហាអំពើពុករលួយ លួចបន្លំ ទំនាស់ផលប្រយោជន៍ និងការប្រើប្រភពធនធានខុសគោលដៅ។

**ឃ.** ធ្វើសវនកម្ម ផ្ទៀងផ្ទាត់ដោយអនុលោមតាមច្បាប់ និងរាយការណ៍ឱ្យមានតម្លាភាព

**ង.** ប៉ាន់ប្រមាណ គ្រប់គ្រង និងកាត់បន្ថយហានិភ័យជាប្រចាំ

**ច.** ធានាថាការទទួលយកធនធាន មិនប៉ះពាល់ដល់ឯករាជ្យភាពរបស់ខ្លួនឡើយ

[11] ធនធានគួរតែត្រូវបានយល់នៅក្នុងន័យទូលំទូលាយដែលរួមបញ្ចូលអ្វីដែលអង្គការត្រូវការដើម្បីបំពេញបេសកកម្មរបស់ខ្លួន, រួមបញ្ចូលប៉ុន្តែមិនមានកំណត់: មូលនិធិ បុគ្គលិក ទំនិញ បរិក្ខា ពេលវេលា ដី ទឹក ខ្យល់ ផលិតផលធម្មជាតិ និងបរិស្ថាន។

## ៨. សទ្ទានុក្រម

សម្រាប់គោលបំណងនៃបទដ្ឋានស្នូលជំនួយមនុស្សធម៌ និយមន័យមួយចំនួនដូចខាងក្រោមត្រូវបានអនុវត្តៈ

**គណនេយ្យភាពៈ** ជាដំណើរការនៃការប្រើប្រាស់អំណាចប្រកបដោយភាពទទួលខុសត្រូវ ដោយមានគណនេយ្យភាពចំពោះអ្នកពាក់ព័ន្ធនានា ជាពិសេសអ្នកដែលទទួលរងផលប៉ះពាល់ពីការរំលោភបំពាននៃអំណាច។

**សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយៈ** ជាចំនួនសរុបនៃបុរស ស្ត្រី ក្មេងប្រុស និងក្មេងស្រី ជាមួយនឹងតម្រូវការ ភាពងាយរងគ្រោះ និងសមត្ថភាពផ្សេងៗគ្នាដែលរងគ្រោះដោយគ្រោះមហន្តរាយ ជម្លោះ ភាពក្រីក្រ និងវិបត្តផ្សេងៗទៀតនៅតំបន់ជាក់លាក់ណាមួយ។

**ឯកសារៈ** រាល់ទម្រង់បែបបទនៃកំណត់ត្រា កិច្ចពិភាក្សា កិច្ចព្រមព្រៀង ការសម្រេចចិត្ត និង/ឬសកម្មភាពណាមួយដែលបានព្រងព្រៀងគ្នា។

**ប្រសិទ្ធភាពៈ** ជាវិសាលភាពទៅលើអ្វីដែលសកម្មភាពជំនួយមនុស្សធម៌សម្រេចតាមគោលបំណងរបស់ខ្លួន។

**ប្រសិទ្ធផលៈ** ជាវិសាលភាពលទ្ធផលទៅលើអ្វីដែលកម្មវិធីមនុស្សធម៌ទាំងគុណភាពនិងបរិមាណសម្រេចបានដែលជាលទ្ធផលនៃធាតុចូល។

**ការចូលរួមៈ** ដំណើរការមួយដែលអង្គការធ្វើការទាក់ទង ពិគ្រោះយោបល់ និង/ឬផ្តល់ឱ្យមានការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធដើម្បីធានាថារាល់កង្វល់ បំណង ការរំពឹងទុក សេចក្តីត្រូវការ សិទ្ធិ និងឱកាសរបស់ពួកគេត្រូវបានពិចារណា ក្នុងការបង្កើត អនុវត្ត និងពិនិត្យកម្មវិធីទាំងនោះដើម្បីជួយដល់ពួកគេ។

**សកម្មភាពមនុស្សធម៌ៈ** សកម្មភាពមួយដែលមានគោលបំណងសង្គ្រោះជីវិត កាត់បន្ថយការរងទុក្ខវេទនា និងរក្សាបាននូវសេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងអំឡុងពេល និងបន្ទាប់ពីគ្រោះមហន្តរាយដោយធម្មជាតិ និងដោយមនុស្ស ក៏ដូចជាសកម្មភាពផ្សេងទៀត ដើម្បីការពារ និងរៀបចំ។[12]

**អង្គការៈ** អង្គភាពដែលមានរចនាសម្ព័ន្ធគ្រប់គ្រង និងអំណាច ដើម្បីអនុវត្តបទដ្ឋានស្នូលជំនួយមនុស្សធម៌

**ដៃគូៈ** អង្គការដែលធ្វើការរួមគ្នា ដោយមានការរៀបចំជាផ្លូវការ ដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ដោយមានតួនាទី និងការទទួលខុសត្រូវព្រមព្រៀងគ្នា និងច្បាស់លាស់។

**គោលនយោបាយៈ** សេចក្តីថ្លែងការណ៍ដែលបានចងក្រងជាឯកសារក្នុងបំណង និងវិធានការសម្រាប់ធ្វើការសម្រេចចិត្ត។

**ការការពារៈ** សកម្មភាពទាំងអស់ដែលមានគោលបំណងធានាឱ្យបានការគោរពយ៉ាងពេញលេញ និងស្មើគ្នា

[12] ដូចដែលបានកំណត់ក្នុងមគ្គុទេសក៏សាកល្បងនៃការវាយតំលៃសកម្មភាពមនុស្សធម៌ ALNAP ២០១៣ ទំព័រ ទី១៤

សម្រាប់សិទ្ធិរបស់បុគ្គលគ្រប់រូប ដោយមិនគិតពីអាយុ ភេទ ជនជាតិភាគតិច សង្គម សាសនា ឬក្រុមដទៃទៀត។ វាលើសពីសកម្មភាពដើម្បីសង្គ្រោះជីវិតបន្ទាន់ដែលតែងតែផ្តោតការយកចិត្តទុកដាក់ក្នុងអំឡុងពេលគ្រោះអាសន្ន។

**គុណភាព៖** សំដៅលើបណ្តុំនៃរូបភាព និងចរិកលក្ខណៈរបស់ជំនួយមនុស្សធម៌ទាំងឡាយណាដែលគាំទ្រដល់សមត្ថភាពរបស់ខ្លួន (ទាន់ពេលវេលា) ដើម្បីបំពេញតម្រូវការ និងការរំពឹងទុកដែលបានបញ្ជាក់ ឬបង្ហាញ និងគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សដែលយើងមានបំណងជួយ។

**ភាពធន់៖** សមត្ថភាពរបស់សហគមន៍ ឬសង្គមដែលប្រឈមទៅនឹងមុខសញ្ញាគ្រោះថ្នាក់ ដើម្បីអាចទប់ទល់ ទទួលយក សម្របខ្លួន និងស្តារឡើងវិញពីផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

**បុគ្គលិក៖** ជាអ្នកតំណាងរបស់អង្គការមួយ គិតរួមបញ្ចូលទាំងបុគ្គលិកជាតិ អន្តរជាតិ និងអចិន្ត្រៃយ៍ ឬរយៈពេលខ្លី ក៏ដូចជាអ្នកស្ម័គ្រចិត្ត និងទីប្រឹក្សាផងដែរ។

**បទដ្ឋានស្នូលមនុស្សធម៌ស្តីពីគុណភាព និងគណនេយ្យភាព** រួមមានប្រាំបួនការប្តេជ្ញាចិត្ត ដែលអង្គការ និងបុគ្គល ហើយសកម្មភាពរបស់គេទាក់ទងនឹងការឆ្លើយតបជំនួយមនុស្សធម៌អាចប្រើ(CHS)ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងលើគុណភាព និងកាន់តែមានប្រសិទ្ធិភាពខ្ពស់ ចំពោះជំនួយមនុស្សធម៌ដែលបានផ្តល់។ វាក៏ជួយសម្របសម្រួលឲ្យកាន់តែមានគណនេយ្យភាពចំពោះសហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ។ វាអាចធ្វើឲ្យពួកគេដឹងពីអ្វីដែលអង្គការបានប្តេជ្ញា និងជួយពួកគេជំរុញអង្គការទាំងនោះទទួលខុសត្រូវលើការប្តេជ្ញានោះ។

ក្នុងខៈណៈជាបទដ្ឋានស្នូលពិពណ៌នាពីធាតុសំខាន់ៗនៃគោលការណ៍គណនេយ្យភាព និងគុណភាពក្នុងការងារផ្តល់ជំនួយមនុស្សធម៌។ អង្គការមនុស្សធម៌អាចប្រើប្រាស់វាជាការស្ម័គ្រចិត្តធ្វើឲ្យស្របជាមួយនឹងនីតិវិធីដែលមានស្រាប់ក្នុងអង្គភាពរបស់ខ្លួន។ វាក៏អាចប្រើប្រាស់ជាគោលការណ៍មូលដ្ឋានក្នុងការផ្ទៀងផ្ទាត់ការអនុវត្តន៍ការងារផងដែរ។

បទដ្ឋានស្នូលមនុស្សធម៌ ជាលទ្ធផលនៃការពិគ្រោះយោបល់រយៈពេល១២ខែក្នុង៣ដំណាក់កាលក្រោមការសម្របសម្រួលពីHAP ភីផលអ៊ិនអេដ និងគម្រោងការស្វ៊ែរដែលក្នុងកំឡុងពេលនោះភ្នាក់ងារ មនុស្សធម៌ សហគមន៍ និងជនរងគ្រោះដោយគ្រោះមហន្តរាយ អង្គការមិនមែនរដ្ឋាភិបាលបណ្តាញផ្សេងៗ រដ្ឋាភិបាល អង្គការសហប្រជាជាតិម្ចាស់មូលនិធិ និងស្ថាប័នសិក្សាបានវិភាគយ៉ាងហ្មត់ចត់ទៅលើខ្លឹមសារនៃបទដ្ឋានស្នូលមនុស្សធម៌ ហើយបានសាកល្បងនៅទីស្នាក់ការកណ្តាល និងនៅមូលដ្ឋាន។


corehumanitarianstandard

@corehumstandard

www.corehumanitarianstandard.org | info@corehumanitarianstandard.org



ISBN: 978-2-9701015-5-0